ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
លេខ : ៥៣៧ ស.ហ.វ.ប្រក.អធច

# ប្រកាសអន្តរក្រសួង
# ស្តីពី
# ការផាកពិន័យ ដែលស្ថិតក្រោមសមត្ថកិច្ចរបស់ក្រសួងទេសចរណ៍

២០២៤

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ..[illegible]...សហវ.ប្រក.២០២៤

# ប្រកាសអន្តរក្រសួង
## ស្តីពី
## ការផាកពិន័យ ដែលស្ថិតក្រោមសមត្ថកិច្ចរបស់ក្រសួងទេសចរណ៍

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** **រដ្ឋមន្ត្រីក្រសួងទេសចរណ៍**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨២២/០១០ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ២៥៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ៧២ អនក្រ.បក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ១៨ អនក្រ.បក ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ២៥ អនក្រ.បក ចុះថ្ងៃទី៩ ខែមីនា ឆ្នាំ២០២០ ស្តីពីការគ្រប់គ្រងចំណូលសេវារបស់អង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីគោលការណ៍ និងនីតិវិធីបន្ថែមសម្រាប់ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធក្នុងក្របខ័ណ្ឌនៃការផ្ទេរមុខងារ និងការបែងចែកចំណូលមិនមែនសារពើពន្ធ ពីរដ្ឋបាលថ្នាក់ជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងទេសចរណ៍ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១** _

ការផាកពិន័យ ដែលស្ថិតក្រោមសមត្ថកិច្ចរបស់ក្រសួងទេសចរណ៍ ត្រូវបានរៀបចំជាបញ្ជីផាកពិន័យដែលមានរាយលម្អិតអំពីប្រភេទបទល្មើស និងកម្រិតទឹកប្រាក់ពិន័យទៅតាមប្រភេទបទល្មើសនីមួយៗ ដូចមានចែងក្នុងឧបសម្ព័ន្ធទី១ និងឧបសម្ព័ន្ធទី២ នៃប្រកាសអន្តរក្រសួងនេះ។

ឧបសម្ព័ន្ធទី១ : បញ្ជីផាកពិន័យ ដែលស្ថិតក្រោមសមត្ថកិច្ចរបស់រដ្ឋបាលកណ្តាលក្រសួងទេសចរណ៍

ឧបសម្ព័ន្ធទី២: បញ្ជីផាកពិន័យ ដែលក្រសួងទេសចរណ៍ធ្វើប្រតិភូកម្មមុខងារជូនរដ្ឋបាលរាជធានី ខេត្ត។

**ប្រការ២** _

ការបង់ប្រាក់ផាកពិន័យ ត្រូវបានចាត់ទុកថាជាករណីដោយឡែក សម្រាប់ការដោះបន្ទុកលើប្រភេទបទល្មើស ដែលសាមីជនបានប្រព្រឹត្តតែប៉ុណ្ណោះ។ ចំពោះការស្នើសុំអាជ្ញាបណ្ណទេសចរណ៍ថ្មី ឬបន្តអាជ្ញាបណ្ណទេសចរណ៍ តម្រូវឱ្យម្ចាស់សេវាកម្ម ឬម្ចាស់អាជីវកម្ម ត្រូវបង់ថ្លៃអាជ្ញាបណ្ណទេសចរណ៍ ទៅតាមតម្លៃដែលបានកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងទេសចរណ៍ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ៣** _

ក្នុងករណីដែលអ្នកប្រព្រឹត្តល្មើសនឹងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តស្តីពីទេសចរណ៍ មានការយឺតយ៉ាវមិនបានបង់ប្រាក់ផាកពិន័យនៅក្នុងឥណប្រតិទាន(កាលបរិច្ឆេទតម្រូវឱ្យបង់ប្រាក់)ដែលបានកំណត់ នោះចំនួនទឹកប្រាក់ផាកពិន័យនឹងត្រូវដំឡើងជាទ្វេដង នៃកម្រិតទឹកប្រាក់ផាកពិន័យដែលបានកំណត់នៅក្នុងឧបសម្ព័ន្ធទី១ និងឧបសម្ព័ន្ធទី២ នៃប្រកាសអន្តរក្រសួងនេះ។ ប៉ុន្តែចំនួនទឹកប្រាក់អតិបរមាសម្រាប់ការផាកពិន័យទ្វេដងនេះត្រូវបានកំណត់ត្រឹម ២០លានរៀល ប៉ុណ្ណោះ។

**ប្រការ៤ ._**

ការផាកពិន័យលើប្រភេទបទល្មើសនីមួយៗ ត្រូវអនុវត្តតាមនីតិវិធីដែលកំណត់ដោយរដ្ឋមន្ត្រីក្រសួងទេសចរណ៍។

**ប្រការ៥ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៦ ._**

ប្រកាសអន្តរក្រសួងនេះ មានអានុភាពអនុវត្តចាប់ពីថ្ងៃទី១ ខែតុលា ឆ្នាំ២០២៤ តទៅ។

**ប្រការ៧ ._**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធនៃក្រសួងទេសចរណ៍ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ... ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៩ ខែ សីហា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រីក្រសួងទេសចរណ៍**

**សុខ សូកេន**

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ៧
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធទី១ នៃប្រកាសអន្តរក្រសួងលេខ០៣៣៧... សហវ.ប្រក.អទច ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២៤ ស្តីពីការផាកពិន័យ ដែលស្ថិតក្រោមសមត្ថកិច្ចរបស់ក្រសួងទេសចរណ៍

## បញ្ជីផាកពិន័យ ដែលស្ថិតក្នុងភារកិច្ចរបស់រដ្ឋបាលកណ្តាលក្រសួងទេសចរណ៍

| លេខរៀងបទល្មើស | | បរិយាយ | កម្រិតទឹកប្រាក់ដែលត្រូវពិន័យ (រៀល) |
|---|---|---|---|
| | ក. ប្រភេទបទល្មើសទូទៅ ចំពោះអាជ្ញាបណ្ណទេសចរណ៍ដែលត្រូវចេញដោយក្រសួងទេសចរណ៍ | | |
| ១ | ១- | ការផ្សព្វផ្សាយព័ត៌មានមិនពិតពាក់ព័ន្ធនឹងការធ្វើអាជីវកម្មលើវិស័យទេសចរណ៍ | ៣០០ ០០០ |
| ២ | ២- | គ្មានបញ្ជីតារាងដែលបញ្ជាក់ពីតម្លៃសេវាកម្ម ឬ មុខម្ហូបអាហារភេសជ្ជៈនីមួយៗ | ៣៥០ ០០០ |
| ៣ | ៣- | ការផ្លាស់ប្តូរទីតាំងដែលមិនបានជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងទេសចរណ៍ក្នុងអំឡុងរយៈពេលសុពលភាពនៃអាជ្ញាបណ្ណ | ៦០០ ០០០ |
| ៤ | ៤- | ការមិនសហការប្តឹង ឬ រាយការណ៍ជាបន្ទាន់ទៅអាជ្ញាធរមានសមត្ថកិច្ចពីសកម្មភាពរបស់ភ្ញៀវទេសចរ ឬ សកម្មភាពផ្សេងដែលកើតមកលើភ្ញៀវទេសចរនូវសកម្មភាព ដែលច្បាប់បានហាមឃាត់ | ១ ០០០ ០០០ |
| ៥ | ៥- | ការធ្វើកិច្ចព្រមព្រៀងជាមួយរូបវន្តបុគ្គល ឬ នីតិបុគ្គលដែលឋិតនៅក្រោមសមត្ថកិច្ចក្រសួងទេសចរណ៍ដោយគ្មានអាជ្ញាបណ្ណទេសចរណ៍ | ១ ០០០ ០០០ |
| ៦ | ៦- | ការរារាំងដល់មន្ត្រីមានសមត្ថកិច្ចក្នុងការត្រួតពិនិត្យសកម្មភាពអាជីវកម្ម | ១ ០០០ ០០០ |
| | ខ. ប្រភេទបទល្មើសដោយឡែក | | |
| | ១- | កម្រៃអាជ្ញាបណ្ណទេសចរណ៍សម្រាប់ការីទេសចរណ៍ និងភ្នាក់ងារទេសចរណ៍ | |
| | ១.១- | ការីទេសចរណ៍ដែលនាំភ្ញៀវទេសចរសកម្សាន្តក្រៅព្រះរាណាចក្រកម្ពុជា (Outbound Tour Operators) | |
| ៧ | - | ការធ្វើអាជីវកម្មដោយគ្មានអាជ្ញាបណ្ណ | ២ ០០០ ០០០ |
| ៨ | - | អាជ្ញាបណ្ណហួសសុពលភាព | ២ ០០០ ០០០ |
| | ១.២- | ការីទេសចរណ៍ដែលនាំភ្ញៀវទេសចរចូលមកកម្សាន្តក្នុងព្រះរាជាណាចក្រកម្ពុជា (Inbound Tour Operators) | |
| ៩ | - | ការធ្វើអាជីវកម្មដោយគ្មានអាជ្ញាបណ្ណ | ២ ០០០ ០០០ |
| ១០ | - | អាជ្ញាបណ្ណហួសសុពលភាព | ២ ០០០ ០០០ |
| | ១.៣- | ការីទេសចរណ៍ដែលនាំភ្ញៀវទេសចរកម្សាន្តក្នុងព្រះរាជាណាចក្រកម្ពុជា (Domestic Tour Operators) | |
| ១១ | - | ការធ្វើអាជីវកម្មដោយគ្មានអាជ្ញាបណ្ណ | ២ ០០០ ០០០ |
| ១២ | - | អាជ្ញាបណ្ណហួសសុពលភាព | ២ ០០០ ០០០ |
| | ១.៤- | ភ្នាក់ងារទេសចរណ៍ (Travel Agent) | |
| ១៣ | - | ការធ្វើអាជីវកម្មដោយគ្មានអាជ្ញាបណ្ណ | ២ ០០០ ០០០ |
| ១៤ | - | អាជ្ញាបណ្ណហួសសុពលភាព | ២ ០០០ ០០០ |
| | ១.៥- | ភ្នាក់ងារទេសចរណ៍ក្នុងស្រុក (Domestic Travel Agent) | |
| ១៥ | - | ការធ្វើអាជីវកម្មដោយគ្មានអាជ្ញាបណ្ណ | ២ ០០០ ០០០ |
| ១៦ | - | អាជ្ញាបណ្ណហួសសុពលភាព | ២ ០០០ ០០០ |
| | ២- | អាជីវកម្មសណ្ឋាគារ និងសេវាកម្មស្នាក់នៅ | |
| | ២.១- | សណ្ឋាគារ ឬ សណ្ឋាគារអាផាតមិន ឬ សណ្ឋាគារស្វ៊ីត ឬ សណ្ឋាគាររីសត ឬ ប៊ីងហ្គាឡូ ឬ ម៉ូតែល ឬ ឡូដ៍ (Lodge) | |
| | ២.១.១- | ចំណុះចាប់ពី ២១បន្ទប់ ដល់ ១០០បន្ទប់ | |
| ១៧ | - | ការធ្វើអាជីវកម្មដោយគ្មានអាជ្ញាបណ្ណ | ២ ០០០ ០០០ |
| ១៨ | - | អាជ្ញាបណ្ណហួសសុពលភាព | ២ ០០០ ០០០ |

| លេខរៀងបទល្មើស | | បរិយាយ | កម្រិតទឹកប្រាក់ដែលត្រូវពិន័យ (រៀល) |
|---|---|---|---|
| | ២.១.២- | ចំណុះចាប់ពី ១០១បន្ទប់ ដល់ ១៥០បន្ទប់ | |
| ១៩ | - | ការធ្វើអាជីវកម្មដោយគ្មានអាជ្ញាបណ្ណ | ៣ ០០០ ០០០ |
| ២០ | - | អាជ្ញាបណ្ណហួសសុពលភាព | ២ ០០០ ០០០ |
| | ២.១.៣- | ចំណុះចាប់ពី ១៥១បន្ទប់ ដល់ ២០០បន្ទប់ | |
| ២១ | - | ការធ្វើអាជីវកម្មដោយគ្មានអាជ្ញាបណ្ណ | ៣ ៩០០ ០០០ |
| ២២ | - | អាជ្ញាបណ្ណហួសសុពលភាព | ២ ៦០០ ០០០ |
| | ២.១.៤- | ចំណុះចាប់ពី ២០១បន្ទប់ ដល់ ៣០០បន្ទប់ | |
| ២៣ | - | ការធ្វើអាជីវកម្មដោយគ្មានអាជ្ញាបណ្ណ | ៤ ៩៥០ ០០០ |
| ២៤ | - | អាជ្ញាបណ្ណហួសសុពលភាព | ៣ ៣០០ ០០០ |
| | ២.១.៥- | ចំណុះចាប់ពី ៣០១បន្ទប់ ឡើងទៅ | |
| ២៥ | - | ការធ្វើអាជីវកម្មដោយគ្មានអាជ្ញាបណ្ណ | ៦ ០០០ ០០០ |
| ២៦ | - | អាជ្ញាបណ្ណហួសសុពលភាព | ៤ ០០០ ០០០ |
| | ២.២- | ផ្ទះភ្ញៀវ | |
| | ២.២.១- | ចំណុះចាប់ពី ២១បន្ទប់ ដល់ ៩០បន្ទប់ | |
| ២៧ | - | ការធ្វើអាជីវកម្មដោយគ្មានអាជ្ញាបណ្ណ | ២ ០០០ ០០០ |
| ២៨ | - | អាជ្ញាបណ្ណហួសសុពលភាព | ២ ០០០ ០០០ |
| | ២.២.២- | ចំណុះចាប់ពី ៩១បន្ទប់ ដល់ ១០០បន្ទប់ | |
| ២៩ | - | ការធ្វើអាជីវកម្មដោយគ្មានអាជ្ញាបណ្ណ | ២ ២៥០ ០០០ |
| ៣០ | - | អាជ្ញាបណ្ណហួសសុពលភាព | ២ ០០០ ០០០ |
| | ២.២.៣- | ចំណុះចាប់ពី ១០១បន្ទប់ ឡើងទៅ | |
| ៣១ | - | ការធ្វើអាជីវកម្មដោយគ្មានអាជ្ញាបណ្ណ | ៤ ៥០០ ០០០ |
| ៣២ | - | អាជ្ញាបណ្ណហួសសុពលភាព | ៣ ០០០ ០០០ |
| | ២.៣- | កន្លែងបោះជំរុំ | |
| ៣៣ | - | ការធ្វើអាជីវកម្មដោយគ្មានអាជ្ញាបណ្ណ | ២ ០០០ ០០០ |
| ៣៤ | - | អាជ្ញាបណ្ណហួសសុពលភាព | ២ ០០០ ០០០ |
| | ៣- | **អាជីវកម្មភោជនីយដ្ឋាន ឬ អាហារដ្ឋាន** | |
| | ៣.១- | ចំណុះចាប់ពី ១០១នាក់ ដល់ ៣០០នាក់ | |
| ៣៥ | - | ការធ្វើអាជីវកម្មដោយគ្មានអាជ្ញាបណ្ណ | ២ ០០០ ០០០ |
| ៣៦ | - | អាជ្ញាបណ្ណហួសសុពលភាព | ២ ០០០ ០០០ |
| | ៣.២- | ចំណុះចាប់ពី ៣០១នាក់ឡើងទៅ | |
| ៣៧ | - | ការធ្វើអាជីវកម្មដោយគ្មានអាជ្ញាបណ្ណ | ២ ៤០០ ០០០ |
| ៣៨ | - | អាជ្ញាបណ្ណហួសសុពលភាព | ២ ០០០ ០០០ |
| | ៤- | អាជីវកម្មខារ៉ាអូខេ រង្គសាលឌីស្កូតែក និងម៉ាស្សាសុខភាព | |
| | ៤.១- | បទល្មើសពាក់ព័ន្ធនឹងការធ្វើសកម្មភាព | |
| ៣៩ | - | មិនមានបញ្ជីឈ្មោះប្រភេទនៃសេវាកម្មដោយបញ្ជាក់ពីតម្លៃនីមួយៗដល់ភ្ញៀវ | ៥០០ ០០០ |
| ៤០ | - | អនុញ្ញាតឱ្យអនីតិជនចូលក្នុងមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ | ១ ៥០០ ០០០ |

| លេខរៀងបទល្មើស | | បរិយាយ | កម្រិតទឹកប្រាក់ដែលត្រូវពិន័យ (រៀល) |
|---|---|---|---|
| | ៤.២- | ការធ្វើអាជីវកម្មដោយគ្មានអាជ្ញាបណ្ណ ឬ អាជ្ញាបណ្ណហួសសុពលភាព | |
| | ៤.២.១- | ខារ៉ាអូខេ ស្ថិតនៅក្នុងសណ្ឋាគារដែលមានចំណាត់ថ្នាក់ផ្កាយ៤ និងផ្កាយ៥ | |
| | ៤.២.១.១- | ចំណុះចាប់ពី ៥បន្ទប់ ដល់ ១០បន្ទប់ | |
| ៤១ | - | ការធ្វើអាជីវកម្មដោយគ្មានអាជ្ញាបណ្ណ | ២ ០០០ ០០០ |
| ៤២ | - | អាជ្ញាបណ្ណហួសសុពលភាព | ២ ០០០ ០០០ |
| | ៤.២.១.២- | ចំណុះចាប់ពី ១១បន្ទប់ ដល់ ២០បន្ទប់ | |
| ៤៣ | - | ការធ្វើអាជីវកម្មដោយគ្មានអាជ្ញាបណ្ណ | ២ ៤០០ ០០០ |
| ៤៤ | - | អាជ្ញាបណ្ណហួសសុពលភាព | ២ ០០០ ០០០ |
| | ៤.២.១.៣- | ចំណុះចាប់ពី ២១បន្ទប់ ដល់ ៤០បន្ទប់ | |
| ៤៥ | - | ការធ្វើអាជីវកម្មដោយគ្មានអាជ្ញាបណ្ណ | ៤ ៥០០ ០០០ |
| ៤៦ | - | អាជ្ញាបណ្ណហួសសុពលភាព | ៣ ០០០ ០០០ |
| | ៤.២.១.៤- | ចំណុះចាប់ពី ៤១បន្ទប់ ឡើងទៅ | |
| ៤៧ | - | ការធ្វើអាជីវកម្មដោយគ្មានអាជ្ញាបណ្ណ | ៦ ០០០ ០០០ |
| ៤៨ | - | អាជ្ញាបណ្ណហួសសុពលភាព | ៤ ០០០ ០០០ |
| | ៤.២.២- | ម៉ាស្សាសុខភាព | |
| | ៤.២.២.១- | ចំណុះចាប់ពី ១១គ្រែ ឬកៅអី ឡើងទៅ | |
| ៤៩ | - | ការធ្វើអាជីវកម្មដោយគ្មានអាជ្ញាបណ្ណ | ២ ០០០ ០០០ |
| ៥០ | - | អាជ្ញាបណ្ណហួសសុពលភាព | ២ ០០០ ០០០ |
| | ៤.២.៣- | រង្គសាលឌីស្កូតែក ឬ រង្គសាល-ឌីស្កូតែក ស្ថិតនៅក្នុងសណ្ឋាគារដែលមានចំណាត់ថ្នាក់ផ្កាយ៤ និងផ្កាយ៥ | |
| | ៤.២.៣.១- | ចំណុះចាប់ពី ៥០នាក់ ដល់ ១០០នាក់ | |
| ៥១ | - | ការធ្វើអាជីវកម្មដោយគ្មានអាជ្ញាបណ្ណ | ២ ០០០ ០០០ |
| ៥២ | - | អាជ្ញាបណ្ណហួសសុពលភាព | ២ ០០០ ០០០ |
| | ៤.២.៣.២- | ចំណុះចាប់ពី ១០១នាក់ ដល់ ១៥០នាក់ | |
| ៥៣ | - | ការធ្វើអាជីវកម្មដោយគ្មានអាជ្ញាបណ្ណ | ៣ ០០០ ០០០ |
| ៥៤ | - | អាជ្ញាបណ្ណហួសសុពលភាព | ២ ០០០ ០០០ |
| | ៤.២.៣.៣- | ចំណុះចាប់ពី ១៥១នាក់ ដល់ ២០០នាក់ | |
| ៥៥ | - | ការធ្វើអាជីវកម្មដោយគ្មានអាជ្ញាបណ្ណ | ៦ ០០០ ០០០ |
| ៥៦ | - | អាជ្ញាបណ្ណហួសសុពលភាព | ៤ ០០០ ០០០ |
| | ៤.២.៣.៤- | ចំណុះចាប់ពី ២០១នាក់ ឡើងទៅ | |
| ៥៧ | - | ការធ្វើអាជីវកម្មដោយគ្មានអាជ្ញាបណ្ណ | ៩ ០០០ ០០០ |
| ៥៨ | - | អាជ្ញាបណ្ណហួសសុពលភាព | ៦ ០០០ ០០០ |
| | ៥- | អាជីវកម្មកីឡាទេសចរណ៍ | |
| | ៥.១- | ក្លឹបកំសាន្តប៊ូលីង | |
| ៥៩ | - | ការធ្វើអាជីវកម្មដោយគ្មានអាជ្ញាបណ្ណ | ២ ០០០ ០០០ |
| ៦០ | - | អាជ្ញាបណ្ណហួសសុពលភាព | ២ ០០០ ០០០ |

| លេខរៀងបទល្មើស | បរិយាយ | កម្រិតទឹកប្រាក់ដែលត្រូវពិន័យ (រៀល) |
|---|---|---|
| | ៥.២- ក្លឹបហ្វឹកហាត់វាយកូនគោល | |
| | ៥.២.១- ចំណុះមិនលើសពី ១០កន្លែង | |
| ៦១ | - ការធ្វើអាជីវកម្មដោយគ្មានអាជ្ញាប័ណ្ណ | ២ 000 000 |
| ៦២ | - អាជ្ញាប័ណ្ណហួសសុពលភាព | ២ 000 000 |
| | ៥.២.២- ចំណុះចាប់ពី ១០កន្លែង ដល់ ៥០កន្លែង | |
| ៦៣ | - ការធ្វើអាជីវកម្មដោយគ្មានអាជ្ញាប័ណ្ណ | ៣ 000 000 |
| ៦៤ | - អាជ្ញាប័ណ្ណហួសសុពលភាព | ២ 000 000 |
| | ៥.២.៣- ចំណុះចាប់ពី ៥១កន្លែង ឡើងទៅ | |
| ៦៥ | - ការធ្វើអាជីវកម្មដោយគ្មានអាជ្ញាប័ណ្ណ | ៦ 000 000 |
| ៦៦ | - អាជ្ញាប័ណ្ណហួសសុពលភាព | ៤ 000 000 |
| | ៥.៣- ក្លឹបកីឡាវាយកូនគោល | |
| | ៥.៣.១- ចំណុះ ៩រន្ធ | |
| ៦៧ | - ការធ្វើអាជីវកម្មដោយគ្មានអាជ្ញាប័ណ្ណ | ៦ 000 000 |
| ៦៨ | - អាជ្ញាប័ណ្ណហួសសុពលភាព | ២ 000 000 |
| | ៥.៣.២- ចំណុះចាប់ពី ១៨រន្ធ ឡើងទៅ | |
| ៦៩ | - ការធ្វើអាជីវកម្មដោយគ្មានអាជ្ញាប័ណ្ណ | ១២ 000 000 |
| ៧០ | - អាជ្ញាប័ណ្ណហួសសុពលភាព | ៤ 000 000 |
| | ៥.៤- យន្តហោះ ឬ ឧទ្ធម្ភាចក្រជិះកំសាន្ត | |
| ៧១ | - ការធ្វើអាជីវកម្មដោយគ្មានអាជ្ញាប័ណ្ណ | ៣ 000 000 |
| ៧២ | - អាជ្ញាប័ណ្ណហួសសុពលភាព | ២ 000 000 |
| | ៥.៥- អាជីវកម្មកីឡាទេសចរណ៍ផ្សេងៗទៀត ចំពោះអាជ្ញាប័ណ្ណទេសចរណ៍ដែលត្រូវចេញដោយក្រសួងទេសចរណ៍ | |
| ៧៣ | - ការធ្វើអាជីវកម្មដោយគ្មានអាជ្ញាប័ណ្ណ | ២ 000 000 |
| ៧៤ | - អាជ្ញាប័ណ្ណហួសសុពលភាព | ២ 000 000 |
| | ៦- អាជីវកម្មទេសចរណ៍ MICE ប្រភេទបន្ទប់ប្រជុំ សាលសន្និសីទ និងសាលពិព័រណ៍ | |
| ៧៥ | - ការធ្វើអាជីវកម្មដោយគ្មានអាជ្ញាប័ណ្ណ | ២ 000 000 |
| ៧៦ | - អាជ្ញាប័ណ្ណហួសសុពលភាព | ២ 000 000 |
| | ៧- អាជីវកម្មរមណីយដ្ឋានទេសចរណ៍ | |
| | ៧.១- រមណីយដ្ឋានថ្នាក់ជាតិ | |
| ៧៧ | - ការធ្វើអាជីវកម្មដោយគ្មានអាជ្ញាប័ណ្ណ | ៦ 000 000 |
| ៧៨ | - អាជ្ញាប័ណ្ណហួសសុពលភាព | ៤ 000 000 |
| | ៧.២- រមណីយដ្ឋានថ្នាក់ខេត្ត | |
| ៧៩ | - ការធ្វើអាជីវកម្មដោយគ្មានអាជ្ញាប័ណ្ណ | ៣ 000 000 |
| ៨០ | - អាជ្ញាប័ណ្ណហួសសុពលភាព | ២ ៥00 000 |
| | ៧.៣- រមណីយដ្ឋានថ្នាក់ស្រុក | |
| ៨១ | - ការធ្វើអាជីវកម្មដោយគ្មានអាជ្ញាប័ណ្ណ | ២ ៥00 000 |
| ៨២ | - អាជ្ញាប័ណ្ណហួសសុពលភាព | ២ 000 000 |

| លេខរៀងបទល្មើស | | បរិយាយ | កម្រិតទឹកប្រាក់ដែលត្រូវពិន័យ (រៀល) |
|---|---|---|---|
| | ៧.៤- | រមណីយដ្ឋានថ្នាក់កែច្នៃ | |
| ៨៣ | - | ការធ្វើអាជីវកម្មដោយគ្មានអាជ្ញាបណ្ណ | ២ 000 000 |
| ៨៤ | - | អាជ្ញាបណ្ណហួសសុពលភាព | ២ 000 000 |
| | ៨- | **អាជីវកម្មមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់តំបន់ ថ្នាក់ពិសេស និងថ្នាក់ជាតិ** | |
| | ៨.១- | បទល្មើសពាក់ព័ន្ធនឹងការធ្វើសកម្មភាព | |
| ៨៥ | - | មគ្គុទ្ទេសក៍ទេសចរណ៍មិនពាក់ឯកសណ្ឋាន ឬ សញ្ញាសម្គាល់ដែលចេញដោយក្រសួងទេសចរណ៍ ឬ មន្ទីរទេសចរណ៍ | ២០ 000 |
| ៨៦ | - | ការនាំភ្ញៀវចូលទៅកន្លែងដែលអាជ្ញាធរបានហាមឃាត់ | ៥០ 000 |
| ៨៧ | - | ការផ្តល់ព័ត៌មានមិនពិតក្នុងវិស័យទេសចរណ៍ដល់ភ្ញៀវទេសចរ | ៥០ 000 |
| ៨៨ | - | ការមិនគោរពទៅតាមក្រមប្រតិបត្តិវិជ្ជាជីវៈមគ្គុទ្ទេសក៍ទេសចរណ៍ | ៥០ 000 |
| ៨៩ | - | ការពិសាគ្រឿងស្រវឹងក្នុងពេលបំពេញការងារ | ៦០ 000 |
| ៩០ | ៨.២- | ការធ្វើអាជីវកម្មដោយគ្មានអាជ្ញាបណ្ណ | ២ 000 000 |
| ៩១ | ៨.៣- | អាជ្ញាបណ្ណហួសសុពលភាព | ២ 000 000 |
| | ៩- | **អ្នកបកប្រែភាសាបន្តពីមគ្គុទ្ទេសក៍ទេសចរណ៍** | |
| ៩២ | - | ការធ្វើអាជីវកម្មដោយគ្មានអាជ្ញាបណ្ណ | ២ 000 000 |
| ៩៣ | - | អាជ្ញាបណ្ណហួសសុពលភាព | ២ 000 000 |

<u>កំណត់សម្គាល់</u> ៖ ក្នុងករណីមានការយឺតយ៉ាវមិនបានបង់ប្រាក់ផាកពិន័យនៅក្នុងឥណប្រតិទាន(កាលបរិច្ឆេទតម្រូវឱ្យបង់ប្រាក់) នោះចំនួនទឹកប្រាក់ផាកពិន័យនឹងត្រូវដំឡើងជាទ្វេដង នៃកម្រិតទឹកប្រាក់ផាកពិន័យដែលបានកំណត់ក្នុងបញ្ជីផាកពិន័យខាងលើ។ ប៉ុន្តែចំនួនទឹកប្រាក់អតិបរមាសម្រាប់ការផាកពិន័យទ្វេដងនេះ ត្រូវបានកំណត់ត្រឹម ២០លានរៀល ប៉ុណ្ណោះ។

ឧបសម្ព័ន្ធទី២ នៃប្រកាសអន្តរក្រសួងលេខ...៥៣៧... សហវ.ប្រក.អទច ចុះថ្ងៃទី...២៩... ខែ...សីហា... ឆ្នាំ២០២៤ ស្តីពីការផាកពិន័យ ដែលស្ថិតក្រោមសមត្ថកិច្ចរបស់ក្រសួងទេសចរណ៍

## បញ្ជីផាកពិន័យ ដែលក្រសួងទេសចរណ៍ធ្វើប្រតិភូកម្មមុខងារជូនរដ្ឋបាលរាជធានី ខេត្ត

| លេខរៀងបទល្មើស | | ប្រភេទបទល្មើស | កម្រិតទឹកប្រាក់ដែលត្រូវពិន័យ (រៀល) |
|---|---|---|---|
| | ក. ប្រភេទបទល្មើសទូទៅ ចំពោះអាជ្ញាបណ្ណទេសចរណ៍ដែលត្រូវចេញដោយរដ្ឋបាលរាជធានី ខេត្ត | | |
| ១ | ១- | ការផ្សព្វផ្សាយព័ត៌មានមិនពិតពាក់ព័ន្ធនឹងការធ្វើអាជីវកម្មលើវិស័យទេសចរណ៍ | ៣០០ ០០០ |
| ២ | ២- | គ្មានបញ្ជីតារាងដែលបញ្ជាក់ពីតម្លៃសេវាកម្ម ឬ មុខម្ហូបអាហារភេសជ្ជៈនីមួយៗ | ៣៥០ ០០០ |
| ៣ | ៣- | ការផ្លាស់ប្តូរទីតាំងដែលមិនបានជូនដំណឹងជាលាយលក្ខណ៍អក្សរមករដ្ឋបាលរាជធានី ខេត្ត ក្នុងអំឡុងរយៈពេលសុពលភាពនៃអាជ្ញាបណ្ណ | ៦០០ ០០០ |
| ៤ | ៤- | ការមិនសហការប្តឹង ឬ រាយការណ៍ជាបន្ទាន់ទៅអាជ្ញាធរមានសមត្ថកិច្ចពីសកម្មភាពរបស់ភ្ញៀវទេសចរ ឬ សកម្មភាពផ្សេងដែលកើតមកលើភ្ញៀវទេសចរនូវសកម្មភាព ដែលច្បាប់បានហាមឃាត់ | ១ ០០០ ០០០ |
| ៥ | ៥- | ការធ្វើកិច្ចព្រមព្រៀងជាមួយរូបវន្តបុគ្គល ឬ នីតិបុគ្គលដែលឋិតនៅក្រោមសមត្ថកិច្ចរដ្ឋបាលរាជធានី ខេត្ត ដោយគ្មានអាជ្ញាបណ្ណទេសចរណ៍ | ១ ០០០ ០០០ |
| ៦ | ៦- | ការរារាំងដល់មន្ត្រីមានសមត្ថកិច្ចក្នុងការត្រួតពិនិត្យសកម្មភាពអាជីវកម្ម | ១ ០០០ ០០០ |
| | ខ. ប្រភេទបទល្មើសដោយឡែក | | |
| | ១- | អាជីវកម្មសណ្ឋាគារ និងសេវាកម្មស្នាក់នៅ | |
| | ១.១- | សណ្ឋាគារ ឬ សណ្ឋាគារអាផាតមិន ឬ សណ្ឋាគារស្វ៊ីត ឬ សណ្ឋាគាររីសត ឬ ប៊ីងហ្គាឡូ ឬ ម៉ូតែល ឬ ឡូដ៍ (Lodge) ចំណុះមិនលើសពី ២០បន្ទប់ | |
| ៧ | - | ការធ្វើអាជីវកម្មដោយគ្មានអាជ្ញាបណ្ណ | ២ ០០០ ០០០ |
| ៨ | - | អាជ្ញាបណ្ណហួសសុពលភាព | ២ ០០០ ០០០ |
| | ១.២- | ផ្ទះភ្ញៀវ ដែលមានចំណុះមិនលើសពី ២០បន្ទប់ | |
| ៩ | - | ការធ្វើអាជីវកម្មដោយគ្មានអាជ្ញាបណ្ណ | ២ ០០០ ០០០ |
| ១០ | - | អាជ្ញាបណ្ណហួសសុពលភាព | ២ ០០០ ០០០ |
| | ២- | អាជីវកម្មភោជនីយដ្ឋាន ឬ អាហារដ្ឋាន ដែលមានចំណុះមិនលើសពី ១០០នាក់ | |
| ១១ | - | ការធ្វើអាជីវកម្មដោយគ្មានអាជ្ញាបណ្ណ | ២ ០០០ ០០០ |
| ១២ | - | អាជ្ញាបណ្ណហួសសុពលភាព | ២ ០០០ ០០០ |
| | ៣- | អាជីវកម្មប៉ៀរហ្គាឌិន ខារ៉ាអូខេ រង្គសាលឌីស្កូតែក ឬ រង្គសាល-ឌីស្កូតែក | |
| | ៣.១- | បទល្មើសពាក់ព័ន្ធនឹងការធ្វើសកម្មភាព | |
| ១៣ | - | មិនមានបញ្ជីឈ្មោះប្រភេទនៃសេវាកម្មដោយបញ្ជាក់ពីតម្លៃនីមួយៗដល់ភ្ញៀវ | ៥០០ ០០០ |
| ១៤ | - | អនុញ្ញាតឱ្យអនីតិជនចូលក្នុងមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ | ១ ៥០០ ០០០ |
| | ៣.២- | ការធ្វើអាជីវកម្មដោយគ្មានអាជ្ញាបណ្ណ ឬ អាជ្ញាបណ្ណហួសសុពលភាព | |
| | ៣.២.១- | ប៉ៀរហ្គាឌិន | |
| | ៣.២.១.១- | ចំណុះមិនលើសពី ៣០០នាក់ | |
| ១៥ | - | ការធ្វើអាជីវកម្មដោយគ្មានអាជ្ញាបណ្ណ | ២ ០០០ ០០០ |
| ១៦ | - | អាជ្ញាបណ្ណហួសសុពលភាព | ២ ០០០ ០០០ |

| លេខរៀងបទល្មើស | ប្រភេទបទល្មើស | | កម្រិតទឹកប្រាក់ដែលត្រូវពិន័យ (រៀល) |
|---|---|---|---|
| | ៣.២.១.២- | ចំណុះចាប់ពី ៣០១នាក់ ឡើងទៅ | |
| ១៧ | - | ការធ្វើអាជីវកម្មដោយគ្មានអាជ្ញាបណ្ណ | ៣ 000 000 |
| ១៨ | - | អាជ្ញាបណ្ណហួសសុពលភាព | ២ 000 000 |
| | ៣.២.២- | ខារ៉ាអូខេ មិនស្ថិតនៅក្នុងសណ្ឋាគារដែលមានចំណាត់ថ្នាក់ផ្កាយ៤ និងផ្កាយ៥ | |
| | ៣.២.២.១- | ចំណុះមិនលើសពី ១០បន្ទប់ | |
| ១៩ | - | ការធ្វើអាជីវកម្មដោយគ្មានអាជ្ញាបណ្ណ | ២ 000 000 |
| ២០ | - | អាជ្ញាបណ្ណហួសសុពលភាព | ២ 000 000 |
| | ៣.២.២.២- | ចំណុះចាប់ពី ១១បន្ទប់ ដល់ ២០បន្ទប់ | |
| ២១ | - | ការធ្វើអាជីវកម្មដោយគ្មានអាជ្ញាបណ្ណ | ២ ៤00 000 |
| ២២ | - | អាជ្ញាបណ្ណហួសសុពលភាព | ២ 000 000 |
| | ៣.២.២.៣- | ចំណុះចាប់ពី ២១បន្ទប់ ដល់ ៤០បន្ទប់ | |
| ២៣ | - | ការធ្វើអាជីវកម្មដោយគ្មានអាជ្ញាបណ្ណ | ៤ ៥00 000 |
| ២៤ | - | អាជ្ញាបណ្ណហួសសុពលភាព | ៣ 000 000 |
| | ៣.២.២.៤- | ចំណុះចាប់ពី ៤១បន្ទប់ ឡើងទៅ | |
| ២៥ | - | ការធ្វើអាជីវកម្មដោយគ្មានអាជ្ញាបណ្ណ | ៦ 000 000 |
| ២៦ | - | អាជ្ញាបណ្ណហួសសុពលភាព | ៤ 000 000 |
| | ៣.២.៣- | រង្គសាលឌីស្កូតែក ឬ រង្គសាល-ឌីស្កូតែក មិនស្ថិតក្នុងសណ្ឋាគារដែលមានចំណាត់ថ្នាក់ផ្កាយ៤ និងផ្កាយ៥ | |
| | ៣.២.៣.១- | ចំណុះមិនលើសពី ១០០នាក់ | |
| ២៧ | - | ការធ្វើអាជីវកម្មដោយគ្មានអាជ្ញាបណ្ណ | ២ 000 000 |
| ២៨ | - | អាជ្ញាបណ្ណហួសសុពលភាព | ២ 000 000 |
| | ៣.២.៣.២- | ចំណុះចាប់ពី ១០១នាក់ ដល់ ១៥០នាក់ | |
| ២៩ | - | ការធ្វើអាជីវកម្មដោយគ្មានអាជ្ញាបណ្ណ | ៣ 000 000 |
| ៣០ | - | អាជ្ញាបណ្ណហួសសុពលភាព | ២ 000 000 |
| | ៣.២.៣.៣- | ចំណុះចាប់ពី ១៥១នាក់ ដល់ ២០០នាក់ | |
| ៣១ | - | ការធ្វើអាជីវកម្មដោយគ្មានអាជ្ញាបណ្ណ | ៦ 000 000 |
| ៣២ | - | អាជ្ញាបណ្ណហួសសុពលភាព | ៤ 000 000 |
| | ៣.២.៣.៤- | ចំណុះចាប់ពី ២០១នាក់ ឡើងទៅ | |
| ៣៣ | - | ការធ្វើអាជីវកម្មដោយគ្មានអាជ្ញាបណ្ណ | ៩ 000 000 |
| ៣៤ | - | អាជ្ញាបណ្ណហួសសុពលភាព | ៦ 000 000 |
| | ៤- | អាជីវកម្មម៉ាស្សាសុខភាព ស្ប៉ា | |
| | ៤.១- | បទល្មើសពាក់ព័ន្ធនឹងការធ្វើសកម្មភាព | |
| ៣៥ | - | មិនមានបញ្ជីឈ្មោះប្រភេទនៃសេវាកម្មដោយបញ្ជាក់ពីតម្លៃនីមួយៗដល់ភ្ញៀវ | ៥00 000 |
| | ៤.២- | ការធ្វើអាជីវកម្មដោយគ្មានអាជ្ញាបណ្ណ ឬ អាជ្ញាបណ្ណហួសសុពលភាព | |
| | ៤.២.១- | ម៉ាស្សាសុខភាព ចំណុះមិនលើសពី ១០គ្រែ ឬកៅអី | |
| ៣៦ | - | ការធ្វើអាជីវកម្មដោយគ្មានអាជ្ញាបណ្ណ | ២ 000 000 |
| ៣៧ | - | អាជ្ញាបណ្ណហួសសុពលភាព | ២ 000 000 |

| លេខរៀងបទល្មើស | ប្រភេទបទល្មើស | | កម្រិតទឹកប្រាក់ដែលត្រូវពិន័យ (រៀល) |
|---|---|---|---|
| | ៤.២.២- | ស្បា៉ | |
| ៣៨ | - | ការធ្វើអាជីវកម្មដោយគ្មានអាជ្ញាបណ្ណ | ២ ០០០ ០០០ |
| ៣៩ | - | អាជ្ញាបណ្ណហួសសុពលភាព | ២ ០០០ ០០០ |
| | ៤- | អាជីវកម្មកីឡាទេសចរណ៍ (កីឡាស្នូកឃ័រ, ម៉ាស៊ីនហ្គេម, កីឡាជិះដំរី, កីឡាជិះសេះ, កីឡាសៀក, កីឡាជិះកង់វង្វង់, រថយន្ត ឬរថភ្លើងអគ្គិសនី) | |
| ៤០ | - | ការធ្វើអាជីវកម្មដោយគ្មានអាជ្ញាបណ្ណ | ២ ០០០ ០០០ |
| ៤១ | - | អាជ្ញាបណ្ណហួសសុពលភាព | ២ ០០០ ០០០ |
| | ៥- | អាជីវកម្មមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់សហគមន៍ និងថ្នាក់រាជធានី ខេត្ត | |
| | ៥.១- | បទល្មើសពាក់ព័ន្ធនឹងការធ្វើសកម្មភាព | |
| ៤២ | - | មគ្គុទ្ទេសក៍ទេសចរណ៍មិនពាក់ឯកសណ្ឋាន ឬ សញ្ញាសម្គាល់ដែលចេញដោយក្រសួងទេសចរណ៍ ឬ មន្ទីរទេសចរណ៍ | ២០ ០០០ |
| ៤៣ | - | ការនាំភ្ញៀវចូលទៅកន្លែងដែលអាជ្ញាធរបានហាមឃាត់ | ៥០ ០០០ |
| ៤៤ | - | ការផ្តល់ព័ត៌មានមិនពិតក្នុងវិស័យទេសចរណ៍ដល់ភ្ញៀវទេសចរ | ៥០ ០០០ |
| ៤៥ | - | ការមិនគោរពទៅតាមក្រមប្រតិបត្តិវិជ្ជាជីវៈមគ្គុទ្ទេសក៍ទេសចរណ៍ | ៥០ ០០០ |
| ៤៦ | - | ការពិសាគ្រឿងស្រវឹងក្នុងពេលបំពេញការងារ | ៦០ ០០០ |
| ៤៧ | ៥.២- | ការធ្វើអាជីវកម្មដោយគ្មានអាជ្ញាបណ្ណ | ២ ០០០ ០០០ |
| ៤៨ | ៥.៣- | អាជ្ញាបណ្ណហួសសុពលភាព | ២ ០០០ ០០០ |

កំណត់សម្គាល់ ៖ ក្នុងករណីមានការយឺតយ៉ាវមិនបានបង់ប្រាក់ផាកពិន័យនៅក្នុងឥណប្រតិទាន(កាលបរិច្ឆេទតម្រូវឱ្យបង់ប្រាក់) នោះចំនួនទឹកប្រាក់ផាកពិន័យនឹងត្រូវដំឡើងជាទ្វេដង នៃកម្រិតទឹកប្រាក់ផាកពិន័យដែលបានកំណត់ក្នុងបញ្ជីផាកពិន័យខាងលើ។ ប៉ុន្តែចំនួនទឹកប្រាក់អតិបរមាសម្រាប់ការផាកពិន័យទ្វេដងនេះ ត្រូវបានកំណត់ត្រឹម ២០លានរៀល ប៉ុណ្ណោះ។